# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**ភាគីដាក់ឯកសារ:** សហមេធាវីរបស់លោក នួន ជា

**ដាក់ជូន:** អង្គជំនុំជម្រះសាលាដំបូង

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Mar-2016, 15:21
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សម្ងាត់

**ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង:** សម្ងាត់/Confidential

**ចំណាត់ថ្នាក់ប្រភេទឯកសារ:**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:**

**ឈ្មោះមន្ត្រីកត់ត្រា:**

**ហត្ថលេខា:**

---

**សំណើរលើវិធាន ៨៧(៤) របស់នួន ជា ស្នើសុំឲ្យទទួលយកឯកសារចំនួន ១៧ ពាក់ព័ន្ធនឹងសក្ខីកម្មរបស់ ALEXANDER LABAN HINTON (2-TCE-88)**

---

**ដាក់ដោយ៖**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ
Victor KOPPE
លីវ សុវណ្ណា
ព្រុំ ផល្លា
Doreen CHEN
Xiaoyang NIE
Marina HAKKOU
Léa KULINOWSKI

**ចម្លងជូន៖**

**សហមេធាវីរបស់ ខៀវ សំផន**

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

**សហព្រះរាជអាជ្ញា៖**

ជា លាង
Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អវតក សហមេធាវីការពារក្តីលោក នួន ជា ("មេធាវីការពារក្តី") សូមដាក់សំណើនេះសុំឲ្យទទួលយកឯកសារចំនួន ១៧ ជាភស្តុតាង ដើម្បីប្រើប្រាស់នៅអំឡុងពេលសួរដេញដោល Alexander Laban HINTON (2-TCE-88) ("លោក Hinton")។ ឯកសារដែលបានស្នើនេះទាក់ទងទៅនឹងប្រវត្តិ ឯករាជ្យភាព និង ភាពមិនលម្អៀងរបស់លោក Hinton ព្រមទាំងការប្រព្រឹត្តមកលើជនជាតិវៀតណាម និងពុទ្ធសាសនិក។ ការទទួលយកឯកសារទាំងនេះជាភស្តុតាងនឹងអនុញ្ញាតឲ្យមេធាវីការពារក្តីប្រឈមទៅនឹងជំនាញរបស់លោកHinton ព្រមទាំងសៀវភៅរបស់គាត់[1]។ អាស្រ័យហេតុនេះហើយនឹងមានប្រយោជន៍ក្នុងការស្វែងរកការពិត។

## II. ច្បាប់ជាធរមាន

2. រាល់ភស្តុតាងទាំងអស់ត្រូវបានទទួលយក លើកលែងតែមានចែងនៅក្នុងវិធានផ្ទៃក្នុង[2]។ អង្គជំនុំជម្រះអាចបដិសេធសំណើទទួលយកភស្តុតាងក្នុងករណីដែលខ្លួនយល់ឃើញថា ភស្តុតាងមិនមានភាពពាក់ព័ន្ធ ឬក៏ច្រំដែល មិនអាចរកបានក្នុងពេលវេលាសមស្រប មិនអាចបង្ហាញទៅលើអង្គហេតុដែលខ្លួនអាចបង្ហាញ មិនអនុញ្ញាតដោយច្បាប់ ឬក៏នាំឲ្យពន្យារពេលដំណើរការ ឬក៏មិនមានប្រយោជន៍[3]។ ដើម្បីបំពេញលក្ខខណ្ឌនៃវិធាន ៨៧ (៣) ភស្តុតាងដែលត្រូវបានស្នើត្រូវការតែមានភាពពាក់ព័ន្ធ និងអាជឿជាក់បានតាម*ការពិនិត្យបឋម*[4]។ ដោយអនុលោមតាមវិធាន ៨៧ (៤) នៅក្នុងដំណាក់កាលណាក៏ដោយនៅក្នុងអំឡុងពេលសវនាការ ភាគីអាចស្នើសុំឲ្យអង្គជំនុំជម្រះ "ទទួលយកភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត" ដែលជាកម្មវត្ថុនៃភាព

---

[1] **E3/3346**, Alexander Hinton, *Why Did They Kill*?

[2] វិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង។

[3] វិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង។

[4] ឯកសារ **E289/2** "សេចក្តីសម្រេចលើសំណើដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ **E289**) និងចម្លើតតបរបស់ខៀវ សំផន (ឯកសារ **E289/1** )" ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ២៦ ("សេចក្តីសម្រេចលើសំណើវិធាន៨៧(៤)")។

តម្រូវនៃវិធាន៨៧(៣)[5]។ ខណៈដែលវិធាន ៨៧(៤) ចែងថា ភស្តុតាងដែលត្រូវបានស្នើត្រូវតែមិនអាចរកបាននៅក្នុងនៅមុនពេលបើកសវនាការ អង្គជំនុំជម្រះនេះបកស្រាយថា វាជាភស្តុតាងដែលអាចរកបាននៅមុនពេលចាប់ផ្តើមសវនាការ ប៉ុន្តែមិនអាចរកឃើញដោយមានការយកចិត្តទុកដាក់សមស្របនឹងអាចទទួលយក[6]។

3. នៅក្នុងស្ថានភាពជាក់ស្តែងភស្តុតាងដែលមិន"លើកឡើងដោយតឹងរ៉ឹង" បំពេញបានលក្ខខណ្ឌនេះត្រូវបានទទួលយក៖ គឺនៅពេលដែលភស្តុតាងមានភាពពាក់ព័ន្ធយ៉ាងខ្លាំងទៅឯកសារដែលមានស្រាប់នៅចំពោះមុខអង្គជំនុំជម្រះ និងនៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យមានប្រភពដើម្បីវាយតម្លៃ, នៅពេលដែលភស្តុតាងដែលលើកឡើងជាភស្តុតាងដោះបន្ទុក និងតម្រូវឲ្យមានការវាយតម្លៃ ដើម្បីកុំឲ្យប៉ះពាល់ដល់យុត្តិធម៌, ឬក៏នៅពេលដែលភាគីផ្សេងទៀតមិនបានបដិសេធនឹងភស្តុតាង[7]។

### III. អំណះអំណាង

## ក. សេចក្តីសង្ខេបរបស់ឯកសារ

### *(i) ឯកសារទាក់ទងនឹងប្រវត្តិ និងវិធីសាស្ត្រ*

4. ឯកសារទី១ គឺប្រវត្តិសង្ខេបរបស់លោក Hinton គិតមកត្រឹមឆ្នាំ២០១២ ដែលអាចរកបាននៅគេហទំព័រសកលវិទ្យាល័យ Rutgers-Newark (សហរដ្ឋអាមេរិក) ដែលគាត់ធ្វើជាសាស្ត្រាចារ្យនៅទីនោះ[8]។ ឯកសារនេះត្រូវភ្ជាប់ជា **ឯកសារភ្ជាប់សាធារណៈ ១** និង មានបញ្ជីនូវមុខងាររបស់គាត់ដែលធ្លាប់មាន ឬកំពុងតែមាន និងអំពីការសិក្សា ការធ្វើការស្រាវជ្រាវដោយកន្លែង សៀវភៅដែលគាត់បាននិពន្ធ ឬ បានពិនិត្យ និងអត្ថបទបង្រៀន សិក្ខាសាលា និងសន្និសិទ្ធដែលគាត់បានចូល

---

[5] រយៈពេលមួយឆ្នាំនៅក្នុងសវនាការសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ភាគីអាចដាក់សំណើវិធាន ៨៧(៤) ស្នើសុំឲ្យទទួលយកឯកសារដែលមាននៅក្នុងសំណុំរឿង ប៉ុន្តែមិនត្រូវបានបញ្ចូលនៅក្នុងបញ្ជីឯកសារដែលទទួលយកដោយអង្គជំនុំជម្រះ បើទោះជាឯកសារទាំងអស់នោះត្រូវបានបង្ហាញដោយសហព្រះរាជអាជ្ញាដែលនាំឲ្យមានការស្នើឡើង។ សូមមើលប្រតិចារិកថ្ងៃទី២៦ ខែ មករា ឆ្នាំ២០១៦ ទំព័រ ២៤។

[6] ឯកសារ **E313** "សាលក្រមសំណុំរឿង ០០២/០១" ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២៥។ ឯកសារ **E289/2** "សេចក្តីសម្រេចលើសំណើវិធាន៨៧(៤)" កថាខណ្ឌ ៣។

[7] សូមមើល ឯកសារ **E289/2** "សេចក្តីសម្រេចលើសំណើវិធាន៨៧(៤)" កថាខណ្ឌ ៣។

[8] ប្រភព http://dga.rutgers.edu/wp-content/uploads/2012/10/HintonCV.DGA10.28.12.pdf.

រួម។ ឯកសារនេះបង្ហាញពីប្រវត្តិ និងជំនាញរបស់លោក Hinton ដែលពាក់ព័ន្ធនឹងការតែងតាំងគាត់ជាអ្នកជំនាញនៅក្នុងសំណុំរឿងនេះ។ បន្ថែមពីលើនេះ បញ្ជីអត្ថបទដែលបានបោះពុម្ព អត្ថបទបង្រៀន សិក្ខាសាលា និងសន្និសិទ្ធ បង្ហាញអំពីជំនាញរបស់លោក Hinton អំពីមូលហេតុសង្គមដែលនាំឲ្យមានការសម្លាប់ក្នុងទ្រង់ទ្រាយធំ (ដែលបំពេញតម្រូវថា ជាអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា) ធ្វើឡើងដោយជនដែលដល់ អំពីបរិបទសង្គមដែលនាំឲ្យមានអំពើបែបនេះ ព្រមទាំងផលប៉ះពាល់មកលើជនរងគ្រោះ។ ប្រវត្តិរូបសង្ខេបក៏បង្ហាញថា នៅបន្ទាប់មកលោក Hinton ចាប់ផ្តើមការវិភាគលើជនរងគ្រោះនៃការសម្លាប់បែបនេះ និងការស្វះស្វែងរកយុត្តិធម៌សម្រាប់ខ្លួនដោយរួមមានអំពីមូលហេតុ តួនាទី និងភាពមានកំណត់នៃយុត្តធម៌សម័យអន្តរកាល។ ពិសេសជាងនេះទៅទៀត ប្រវត្តិរូបសង្ខេបនេះបង្ហាញថា នៅក្នុងជំនាញរបស់គាត់មិនមានរួមបញ្ចូលអំពីការប្រព្រឹត្តមកលើជនជាតិភាគតិចនៅប្រទេសកម្ពុជា ជាពិសេសជនជាតិវៀតណាម និងពុទ្ធាសាសនិកនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ឬក៏មិនបញ្ចូលរចនាសម្ព័ន្ធរបស់កម្ពុជាជាប្រជាធិបតេយ្យ ឬក៏ដំណើរការរបស់ ស២១ ដែលសហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងបញ្ជីសាក្សីរបស់ខ្លួននោះទេ។ អាស្រ័យហេតុនេះហើយ ឯកសារ១ គឺពាក់ព័ន្ធទៅនឹងការបង្កើតពីវិសាលភាពនៃជំនាញរបស់លោក Hinton ។

5. ឯកសារ២ គឺជាអត្ថបទដកស្រង់ចេញពីភាគទីបីនៃ *The Encyclopedia of Genocide and Crimes Against Humanity* ដែលបានបោះពុម្ពនៅឆ្នាំ២០០៥ ដែលលោក Hinton ឲ្យអត្ថន័យ "វប្បធម៌នរវិទ្យា" (**ឯកសារភ្ជាប់សាធារណៈ២**) ។ លោក Hinton និយាយជាពិសេសថា "នរវិទ្យាគឺការសិក្សាអំពីមនុស្សតាមពេល និងទីកន្លែង ត្រូវបានកំណត់ដោយគំនិតវប្បធម៌ ជាវិធីពិសេសមួយ (រាប់តាំងពីការវិភាគពីរាងកាយ រហូតទៅដល់ការវិភាគជាតិពន្ធុសាស្ត្រដល់ទីកន្លែង) និងគំនិតបែបជំនឿ"។ ឯកសារនេះមានទំនាក់ទំនងក្នុងការកំណត់អំពីប្រវត្តិលោក Hinton និងជំនាញរបស់គាត់ និងអាស្រ័យហេតុនេះហើយជួយក្នុងការកំណត់អំពីវិធីដែលលោក Hinton កំណត់ចំពោះហេតុការដែលបានកើតឡើងនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។

6. ឯកសារ ៣ ជាអត្ថបទសរសេរដោយ Volodymyr Dibrova នៅ Ukrainian Weekly សម្រាប់ថ្ងៃទី ៣០ ខែ មិថុនា រហូតដល់ ថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ ២០១៣ ដែលមានចំណងជើងថា "ផែនទីនៃការអត់ឃ្លាន ជាគម្រោងថ្មីមួយសម្រាប់ Harvard" (**ឯកសារភ្ជាប់សាធារណៈ ៣**)។ អ្នកនិពន្ធសរសេរផ្នែកមួយនៃបទសម្ភាសន៍របស់គាត់ជាមួយលោក Hinton ទាក់ទិននឹងប្រធានបទ "ការ

សិក្សាអំពើប្រល័យពូជសាសន៍"។ គាត់សរសេរថា៖

> សាស្ត្រាចារ្យ Hinton បានកត់សម្គាល់ថា ក្រៅតែអំពីវិធីសាស្ត្រ បច្ចេកទេស ដែលមិនអាចខ្វះបាន និង បញ្ហាការដឹកនាំដែលកើតមាននៅគ្រប់ពេលនៃការប្រមូលទិន្នន័យ ការលំបាកនៃការត្រួតពិនិត្យនៃភាពអាចជឿជាក់បានរបស់ប្រភព ការវាយតម្លៃស្ថិតិ និងការប្រៀបធៀបឯកសារផ្លូវការជាមួយនឹងសាក្សីផ្ទាល់ភ្នែក ការសិក្សាអំពីអំពើប្រល័យពូជសាសន៍ នឹងកាន់តែស្មុគ្រស្មាញដោយការពិចារណាទៅលើបញ្ហានយោបាយ[9]។

7. ឯកសារបញ្ជាក់អំពីភាពមិនច្បាស់លាស់ទាក់ទងនឹងជំនាញរបស់ លោក Hinton ខាងនរវិទ្យា និង កំណត់ថា សេចក្តីថ្លែងការអំពីអង្គហេតុដែលធ្វើឡើងដោយលោក Hinton ត្រូវតែបានធ្វើឡើង ដោយការកំណត់នេះនៅក្នុងចិត្តរួចទៅហើយ។

***(ii) ឯកសារទាក់ទងនឹងលោក Hinton ខ្វះភាពអព្យាក្រឹត និង វត្ថុវិស័យ***

8. ឯកសារ៤ គឺជាក្រុមប្រឹក្សាភិបាល និងជាទីប្រឹក្សារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ("DC-Cam") រហូតមកដល់ខែ កុម្ភៈ ឆ្នាំ ២០១៦ យកចេញពីគេហទំព័រ DC-Cam[10]។ លោក Hinton ជា "ទីប្រឹក្សា" មួយរូបចាប់តាំងពីឆ្នាំ២០០៤។ ឯកសារ ៥ គឺជាសេចក្តីសង្ខេបនៃគម្រោងនៃការចងចាំអំពើប្រល័យពូជសាសន៍កម្ពុជា ជាគម្រោងដែលជាការសហការរវាងមជ្ឈមណ្ឌលសិក្សាពីអំពើប្រល័យពូជសាសន៍ និងសិទ្ធិមនុស្ស (បង្កើតឡើង និងគ្រប់គ្រងដោយ លោក Hinton) និង DC-Cam។ គម្រោង "ធ្វើការស្រាវជ្រាវ អំពីមូលហេតុ និង យន្តការនៃអំពើប្រល័យពូជសាសន៍កម្ពុជា ព្រមទាំងវិធី ដែលប្រជាជនកម្ពុជាចងចាំ ដោះស្រាយ និងស្វែងរកការពិត យុត្តិធម៌ និងការផ្សះផ្សាបន្ទាប់ពីអំពើឃោរឃៅរបស់ខ្មែរក្រហម"[11]។ ឯកសារមានក្នុង **ឯកសារភ្ជាប់សាធារណៈ ៤ និង ៥**។ ឯកសារទាំងពីរបង្ហាញអំពីទំនាក់ទំនងរវាងលោក Hinton ដែលជាអ្នកជំនាញដែលត្រូវតែផ្តល់សក្ខីកម្មដោយអព្យាក្រឹត និង ប្រកបដោយវត្ថុវិស័យភាព[12] ជាមួយនិង DC-Cam ដែលជា

---

[9] ឯកសារភ្ជាប់សាធារណៈ ៣ ទំព័រ ២។

[10] ប្រភពhttp://www.d.dccam.org/Abouts/Board/Board.htm .

[11] ប្រភពhttp://www.ncas.rutgers.edu/center-study-genocide-conflict-resolution-and-human-rights/cambodian-genocide-memory-project.

[12] **E215** "សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ" ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១២ កថាខណ្ឌ ១៥។ សូមមើលផងដែរ *Prosecutor v Nahimana et al,* Case No. ICTR-99-52-A, Appeals Judgement, 28 Nov 2007, para. 199; *Prosecutor v. Šešelj*, Case No. IT-03-67-T, Decision on Expert Status of Reynaud Theunens, 12 Feb 2008, para. 29។

អង្គការក្រៅរដ្ឋាភិបាលដែលមានជំហរថា អំពើប្រល័យពូជសាសន៍បានកើតឡើងនៅក្នុងប្រទេសកម្ពុជា។ ឯកសារបញ្ជាក់ថា លោក Hinton មិនអាចផ្តល់ភស្តុតាងដោយអព្យាក្រិត ឬក៏ឯករាជដោយសារតែភស្តុតាងរបស់គាត់អាចត្រូវបានទទួលឥទ្ធិពលដោយការសហការរបស់គាត់ជាមួយ DC-Cam និងអាស្រ័យហេតុនេះហើយវាមិនមែនជាវត្ថុវិស័យនោះទេ ហើយទីពីរគឺថា លោក Hinton មិនទំនងជាប្រកាន់គោលជំហរខុសពីដៃគូរ ដែលគាត់សហការក្នុងគោលបំណងដើម្បីធ្វើមិនឲ្យខូចទំនាក់ទំនងជិតស្និទ្ធ ឬក៏ផលប្រយោជន៍។ អាស្រ័យហេតុនេះហើយ ឯកសារ៤ និង៥មានភាពពាក់ព័ន្ធទៅនឹងជំនាញ ភាពលម្អៀង និងភាពឯករាជ្យរបស់លោក Hinton ។

9. ឯកសារ៦ សន្ទរកថាស្វាគមន៍របស់លោក Hinton អំពីមជ្ឈមណ្ឌលសិក្សាពីអំពើប្រល័យពូជសាសន៍ និងសិទ្ធិមនុស្ស[13] ដែលគាត់បង្កើតឡើងនៅឆ្នាំ ២០០៧[14]។ វាជា **ឯកសារភ្ជាប់ ៦**។ ដោយការស្វាគមន៍ខ្លីដែលចាប់អារម្មណ៍នឹងមជ្ឈមណ្ឌលលោក Hinton បានផ្តល់នូវកត្តាជំរុញផ្ទាល់ខ្លួនរបស់លោកក្នុងការបង្កើតមជ្ឈមណ្ឌលថា៖

> ផ្លូវរបស់ខ្ញុំក្នុងការបង្កើតមជ្ឈមណ្ឌលនេះគឺនៅក្នុងទស្សវត្សរ៍ទី៩០ ដែលខ្ញុំបានធ្វើដំណើរទៅកាន់ប្រទេសកម្ពុជាក្នុងនាមជានិស្សិតបញ្ចប់ការសិក្សាផ្នែកនរវិទ្យា។ នៅទីនោះ **ខ្ញុំបានឃើញផលប៉ះពាល់នៃអំពើប្រល័យពូជសាសន៍** និងបានប្តេជ្ញាថា មិនគ្រាន់តែធ្វើការស្រាវជ្រាវអំពីមូលហេតុ និងផលប៉ះពាល់នៃអំពើហិង្សាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងស្វែងរកវិធីក្នុងការទប់ស្កាត់ ដោយធ្វើឲ្យមានការយល់ដឹង និងចាប់ផ្តើមនូវការអប់រំ។ (បញ្ជាក់បន្ថែម)

10. សេចក្តីថ្លែងការនេះផ្តល់នូវព័ត៌មានមានតម្លៃទៅលើទស្សនៈរបស់លោក Hinton ចំពោះកម្ពុជាប្រជាធិបតេយ្យ និងបង្ហាញនូវកត្តាជំរុញនូវការស្រាវជ្រាវរបស់គាត់។ វាថែមទាំងបង្ហាញថាលោក Hinton បានសន្និដ្ឋានរួចហើយថា អំពើប្រល័យពូជសាសន៍ពិតជាបានកើតឡើងនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ បើទោះជាសាក្សីអ្នកជំនាញមិនគួរបញ្ចេញទស្សនៈលើអង្គហេតុជ្រុលហួសដែលវាគួរតែជាតួនាទីរបស់អង្គជំនុំជម្រះសាលាដំបូង[15]។ បន្ថែមពីលើនេះវាក៏បង្ហាញអំពី "ភាពពាក់ព័ន្ធផ្លូវចិត្តរបស់គាត់" ដែលកម្មវត្ថុរបស់គាត់រំពឹងទុកថា នឹងផ្តល់សក្ខីកម្ម ដោយសារតែគាត់

---

[13] ប្រភពhttp://www.ncas.rutgers.edu/center-study-genocide-conflict-resolution-and-human-rights/directors-welcome.

[14] ប្រភពhttp://www.ncas.rutgers.edu/center-study-genocide-conflict-resolution-and-human-rights/about-us.

[15] សូមមើល E215 សេចក្តីសម្រេចលើអ្នកជំនាញ កថាខណ្ឌ ១៦។

ហៅថា "ផលប៉ះពាល់នៃអំពើប្រល័យពូជសាសន៍" ដែលជាបទចោទមួយនៅក្នុងសំណុំរឿងនេះ និងដោយសារគាត់បានលះបង់ជីវិតរបស់គាត់ដើម្បីហេតុផលនេះ ដែលវានឹងរារាំងគាត់មិនឱ្យផ្តល់សក្ខីកម្មដោយអព្យាក្រិត និងប្រកបដោយវត្ថុវិស័យ[16]។

11. ឯកសារ ៧ គឺអត្ថបទបោះពុម្ពផ្សាយនៅលើគេហទំព័រសកលវិទ្យាល័យ Rutgers-Newark មានចំណងជើងថា "Hinton បានជួយនាំមកនូវបណ្ណាសារដ្ឋានមួយក្នុងចំនោមបណ្ណាសារដ្ឋានពីររបស់សហរដ្ឋអាមេរិក ទាក់ទងនឹងឯកសារខ្មែរក្រហម ជូន R-N Campus នៅក្នុងឆ្នាំ២០០៥" (**ឯកសារភ្ជាប់សាធារណៈ ៧**)[17] ។ ឯកសារបង្ហាញពីរបៀបដែលលោក Hinton បានជួយនាំឱ្យមានកិច្ចព្រមព្រៀង ដែលតាមរយៈអត្ថបទសរសេរថា "បានជួយនាំមកនូវបណ្ណាសារដ្ឋានមួយក្នុងចំនោមបណ្ណាសារដ្ឋានពីររបស់សហរដ្ឋអាមេរិក ទាក់ទងនឹងឯកសារខ្មែរក្រហម ជូន R-N Campus នៅក្នុងឆ្នាំ ២០០៥" ដែល*ក្នុងចំណោមនោះ* "បានជួយ [...] មន្ត្រីអង្គការសហប្រជាជាតិ កាត់ទោសអ្នកដែលពាក់ព័ន្ធនឹងការសម្លាប់"[18]។ អាស្រ័យហេតុនេះហើយ វាបង្ហាញឱ្យឃើញថា លោក Hinton អាចមានការចូលរួមដោយផ្ទាល់ក្នុងការប្រមូល ឬរៀបចំឯកសារ ដែលក្រោយមកត្រូវបានប្រើដោយ អវតក ដែលជាតួនាទីមួយមិនមាននិយាយនៅក្នុងប្រវត្តិសង្ខេបរបស់គាត់ ហើយដែលធ្វើឱ្យប៉ះពាល់ដោយធ្ងន់ធ្ងរទៅដល់ភាពអព្យាក្រិត និង ភាពឯករាជ្យក្នុងឋានៈជាសាក្សីអ្នកជំនាញ។ តាមពិតនៅពេលដែលធ្វើការឱ្យភាគីណាមួយនៅក្នុងដំណើរការនីតិវិធី គឺមិនរារាំងដល់បុគ្គលនោះពីការផ្តល់សក្ខីកម្មក្នុងឋានៈជា អ្នកជំនាញនោះទេ។ ICTY បានសម្រេចថា បុគ្គលមួយរូបដែលដោយសារតែលទ្ធផលនៃ "កាលៈទេសៈពិសេសនៃការពាក់ព័ន្ធរបស់ខ្លួននៅក្នុងការស៊ើបអង្កេត និងការរៀបចំសំណុំរឿងរបស់សហព្រះរាជអាជ្ញា" "ដែលមានភាពជិតស្និទ្ធបំផុតទៅនឹងព្រះរាជអាជ្ញាដែលតំណាងរបស់សំណុំរឿង ដែលត្រូវចាត់ទុកថា ជាអ្នកជំនាញ" វានឹងមិនបង្ហាញពីភាពមិនលម្អៀងសម្រាប់ឱ្យអង្គជំនុំជម្រះពឹងផ្អែកលើឡើយ[19]។ ដោយសារតែគ្មានព័ត៌មានបន្ថែម

---

[16] សូមមើលជើងទំព័រទី៦ខាងលើ។

[17] ប្រភព: http://www.newark.rutgers.edu/about-us/have-you-met-rutgers-newark/alex-hinton

[18] ឯកសារភ្ជាប់ ៧ សាធារណៈ ទំព័រ ២។

[19] *Prosecutor v. Milutinović et al.*, Case IT-05-87-T, Transcripts of 13 July 2006, T.840-841; *Prosecutor v. Milutinović et al.*, Case IT-05-87-T, Decision on Prosecution Request for Certification of Interlocutory Appeal of Decision on Admission of Witness Philip Coo's Expert Report , 30 August 2006, para. 10; *Prosecutor v. Đordević*, Case IT-05-87/1-T, Decision on Defence Notice on Rule 94*bis*, 5 March 2009; *see also* Prosecutor v. *Taylor*, Case SCSL-03-1-T, Decision on Defence Application to Exclude the Evidence of Proposed Prosecution

នៅក្នុងអត្ថបទ វាចាំបាច់ណាស់សម្រាប់មេធាវីការពារក្តីអាចដេញដោលលោក Hinton លើប្រធានបទនេះ លើមូលដ្ឋាន **ឯកសារ ៧** ដើម្បីធ្វើតេសនូវវត្ថុវិស័យ ភាពអព្យាក្រិត និងឯករាជ្យភាពរបស់គាត់។

12. ឯកសារ ៨ គឺជាប្រវត្តិរបស់លោក Hinton ដែលរៀបចំឡើងដោយសកលវិទ្យាល័យ Rutgers-Newark (**ឯកសារភ្ជាប់សាធារណៈ ៨**)។ យោងទៅតាមគេហទំព័ររបស់សកលវិទ្យាល័យគាត់ លោក Hinton ក្នុងពេលនេះកំពុងធ្វើការលើសៀវភៅពីរទាក់ទងនឹង អវតក (ដែលត្រូវបានហៅថា "តុលាការខ្មែរក្រហម")។ សៀវភៅទីមួយគឺមានចំណងជើងថា *មនុស្ស ឬ បិសាច? សវនាការកាត់ទោសខ្មែរក្រហមដែលជាអ្នកធ្វើទារុណកម្ម* ដែលនឹងត្រូវបានបោះពុម្ពផ្សាយដោយ សកលវិទ្យាល័យ Duke នៅចុងឆ្នាំនេះ[20]។ គ្រាន់តែចំណងជើងរបស់សៀវភៅក៏បង្ហាញថា លោក Hinton មិនអាចមើលសវនាការនៅអវតកជាវត្ថុវិស័យ និងដោយមិនមានមនោសញ្ចេតនានោះទេ។ នៅពេលដែលសៀវភៅរបស់គាត់ទាក់ទងនឹងសំណុំរឿង០០១ ក៏វានៅតែមានការត្រួតគ្នារវាងសំណុំរឿង ឌុច និងសំណុំរឿង ០០២/០២ ទាក់ទងនឹងមន្ទីរស២១ដែរ។ បន្ថែមពីលើនេះការងាររបស់លោក Hinton ក្នុងការសរសេរសៀវភៅនេះគឺទាក់ទងទៅនឹងការបង្កើតឱ្យឃើញថា តើលោក Hinton តាមរយៈការសិក្សាយ៉ាងលម្អិតអំពីសវនការលើកទីមួយ អាចផ្តល់សក្ខីកម្មក្នុងឋានៈជាសាក្សីជំនាញក្នុងសំណុំរឿង ០០២/០២ ប្រកបដោយភាពអព្យាក្រិត និងប្រកបដោយវត្ថុវិស័យភាពឬក៏អត់។ ជាចុងក្រោយដោយសារតែកម្មវត្ថុនៃសៀវភៅទីពីរមិនត្រូវបានលើកឡើង សំណួរនៅតែបើកចំហរថា តើលោក Hinton មានបំណងសរសេរអំពីសវនាការបច្ចុប្បន្ននេះ ដែលអាចមានឥទ្ធិពលលើលទ្ធភាពក្នុងការផ្តល់សក្ខីកម្ម ឬក៏ខ្លឹមសារនៃសក្ខីកម្មរបស់គាត់ឬក៏អត់។

13. ឯកសារ ៩ គឺជាអត្ថបទសរសេរដោយលោក Hinton មានចំណងជើងថា "សេចក្តីច្រណែនកាផ្សះផ្សារ និងខ្មែរក្រហម( Begrudgement, reconciliation and the Khmer Rouge)" បានបោះពុម្ពក្នុងទស្សនាវដ្តីស្វែងរកការពិតរបស់ DC-Cam លេខ ២០ ខែ សីហា ឆ្នាំ២០០១។ វាជា **ឯកសារភ្ជាប់សាធារណៈ ៩**។ នៅក្នុងអត្ថបទនេះលោក Hinton បានសរសេរទាក់ទងនឹងភាពមានទោសរបស់ជនជាប់ចោទ។ គាត់និយាយទៅដល់ ប៉ុល ពត អៀង សារី នួន ជា ខៀវ សំផន សុន

---

Witness Corinne Dufka or, in the Alternative, to Limit Its Scope and on Urgent Prosecution Request for Decision, 19 June 2008.

[20] ប្រភព: : http://www.ncas.rutgers.edu/center-study-genocide-conflict-resolution-and-human-rights/alex-hinton

សេន និង មេដឹកនាំកំពូលផ្សេងទៀតរបស់កម្ពុជាប្រជាធិបតេយ្យថាជា "ចារីយនៃអំពើប្រល័យពូជសាសន៍"[21]។ គាត់ក៏បានពិពណ៌នាអំពីអ្វីដែលគាត់ហៅថា ខ្មែរក្រហម "គោលនយោបាយប្រល័យពូជសាសន៍"[22] និងលើកឡើងថា "មេដឹកនាំកំពូលរបស់ខ្មែរក្រហមដែលអនុវត្តគោលនយោបាយប្រល័យពូជសាសន៍នេះ"[23]។ ឯកសារ ៩ បង្ហាញច្បាស់ថា លោក Hinton បានធ្វើការវិនិច្ឆ័យរួចទៅហើយអំពីទោសរបស់ធាតុសំខាន់ទាក់ទងនឹងទោសរបស់ជនជាប់ចោទនៅក្នុងសំណុំរឿងនេះគឺអំពីវត្តមាននៃអ្វីដែលហៅថា គោលនយោបាយប្រល័យពូជសាសន៍ និងអំពីតួនាទីរបស់ជនជាប់ចោទ គឺកំពុងតែបង្ហាញភាពលម្អៀងរបស់គាត់ និងធ្វើឱ្យគាត់មិនអាចផ្តល់ភស្តុតាងដោយអព្យាក្រិត និង ប្រកបដោយវត្ថុវិស័យ។ បន្ថែមពីលើនេះអត្ថបទបង្ហាញថា លោក Hinton ខកខានក្នុងការការគាំទ្រអង្គហេតុ ឬ ឯកសារ ក្នុងការនាំទៅដល់ការលើកឡើងរបស់គាត់។ អាស្រ័យហេតុនេះ ឯកសារនេះមានភាពពាក់ព័ន្ធក្នុងការវិធីសាស្ត្រ និង ភាពអាចជឿជាក់បានជាទូទៅទៅលើសៀវភៅរបស់គាត់។

14. ឯកសារ ១០ គឺជាអត្ថបទមានចំណងជើងថា "ហេតុអ្វីបានជាគេសម្លាប់ (១)? ដែលសរសេរដោយលោក Hinton និងបានបោះពុម្ពផ្សាយដោយសារព័ត៌មាន Phnom Penh Post នៅថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ (**ឯកសារភ្ជាប់សាធារណៈ ១០**)។ នៅក្នុងអត្ថបទនោះលោក Hinton លើកឡើងយ៉ាងច្បាស់ថា មានអំពីប្រល័យពូជសាសន៍នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ តាមន័យនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងតាមន័យទូលាយ[24]។ គាត់ក៏បានពន្យល់អំពីគោលបំណងនៃសៀវភៅរបស់គាត់ថា៖

> ដើម្បីយល់អំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា យើងត្រូវតែផ្តោតជាសំខាន់ទៅកាលៈទេសៈទាំងនេះ ឬនិយាយម្យ៉ាងទៀតថា នៅក្នុងបរិបទប្រវត្តិសាស្ត្រទូលាយជាងនេះដែលអំពើប្រល័យពូជសាសន៍បានកើតឡើង។ សៀវភៅរបស់ខ្ញុំផ្តល់ជូននូវ ការយល់ដឹងនៃដំណើរការដែលអំពើប្រល័យពូជាសាសន៍កើតឡើងដែលខ្ញុំបានយោងថាជា "កត្តាជំរុញអំពើប្រល័យពូជសាសន៍ (Genocidal priming)"។ កត្តាជំរុញអំពើប្រល័យពូជសាសន៍រួមមានដូចជា ភាពចលាចលខាងសេដ្ឋកិច្ចសង្គម ការឡើងកាន់អំណាចរបស់អ្នកមនោគមវិជ្ជាក្នុងការបង្កើតសង្គមមួយថ្មីឡើងវិញ ការរៀបចំសង្គមមួយឡើងវិញនៅក្នុងលក្ខណៈដែលធ្វើឱ្យ

[21] ឯកសារភ្ជាប់សាធារណៈ ៩ ទំព័រ ៣០។

[22] ឯកសារភ្ជាប់សាធារណៈ ៩ ទំព័រ ២៥។

[23] ឯកសារភ្ជាប់សាធារណៈ ៩ ទំព័រ ២៥។

[24] ឯកសារភ្ជាប់សាធារណៈ ១០ ទំព័រ ១។

បាត់តម្លៃមនុស្ស ការធ្វើឱ្យអស់អំណាចនិងរហូតដល់សម្លាប់រង្គាលក្រុមជនរងគ្រោះ ការកើតឡើងនូវមនោគមវិជ្ជានៃការស្អប់ដែលធ្វើឱ្យមានការសម្លាប់ ជាដើម[25]។

15. ដូចឯកសារ ៩ ដែរ ឯកសារ ១០ នេះបង្ហាញអំពីភាពលម្អៀងរបស់លោក Hinton ទាក់ទងនឹងបញ្ហាស្នូលនៃសំណុំរឿង និងការមិនអាចផ្តល់ភស្តុតាងដោយអព្យាក្រិត និងប្រកបដោយវត្ថុវិស័យដែលតម្រូវឱ្យគាត់មានក្នុងនាមជាសាក្សីអ្នកជំនាញ។ បន្ថែមពីលើនេះ វាក៏បានបង្ហាញអំពីសារសំខាន់នៅក្នុងបរិបទប្រវត្តិសាស្ត្រទូលាយដើម្បីយល់អំពីអ្វីដែលបានកើតឡើងនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។ វាមានភាពពាក់ព័ន្ធទាំងជំនាញរបស់គាត់ និង ទម្ងន់នៃភស្តុតាងដែលគាត់នឹងត្រូវផ្តល់ជូន។

16. ឯកសារ ១១ គឺជាអត្ថបទដែលបានបោះពុម្ពដោយលោក Hinton នៅសារព័ត៌មាន Phnom Penh Post កាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ដែលមានចំណងជើងថា "ទស្សនៈថា តើមានយុត្តិធម៌ទេនៅប្រទេសកម្ពុជា?" (**ឯកសារភ្ជាប់សាធារណៈ ១១**) ។ នៅក្នុងការពិភាក្សាអំពីសំណុំរឿង ០០២/០១ លោក Hinton សរសេរថា "ដីកាដំណោះស្រាយសំណុំរឿង០០២ ផ្តល់នូវសញ្ញាណនូវអ្វីដែលនឹងមាន។ ឯកសារដែលមានកម្រាស់ ៧៧២ទំព័រ បានលម្អិតអំពី **មេដឹកនាំខ្មែរក្រហម** គ្រប់គ្រងដោយមជ្ឈការ និងប្រត្តិបត្តិ **ម៉ាស៊ីននៃការភ័យរន្ធត់ និង សេចក្តីស្លាប់**"[26]។

17. ឯកសារ ១២ គឺជាអត្ថបទសរសេរដោយ Tom Fawthrop សម្រាប់ *Al-Jazeera* ដែលមានចំណងជើងថា "អស់ពេលហើយសម្រាប់តុលាការខ្មែរក្រហម" កាលបរិច្ឆេទថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣ (**ឯកសារភ្ជាប់សាធារណៈ ១២**)។ លោក Hinton បានស្នើសួរអំពីប្រទេសកម្ពុជា និងអវតក នៅបន្ទាប់ពីមរណៈភាពរបស់ អៀង សារី ដែលគាត់បានហៅរបបកម្ពុជាប្រជាធិបតេយ្យថា "ជារបបមួយបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍"[27]។

18. ឯកសារ ១១ និង ១២ បង្ហាញថាលោក Hinton បានវិនិច្ឆ័យរួចហើយអំពីធាតុសំខាន់នៃសំណុំរឿងអំពីវត្តមាននៃអំពើប្រល័យពូជសាសន៍ និងភាពមានទោសរបស់ជនជាប់ចោទ ដែលនេះបង្ហាញឱ្យឃើញអំពីភាពលម្អៀងរបស់គាត់។ ឯកសារនេះគាំទ្រដល់អំណះអំណាងរបស់មេធាវីការពារក្តីថា

[25] ឯកសារភ្ជាប់សាធារណៈ ១០ ទំព័រ ២។

[26] បញ្ជាក់បន្ថែម។

[27] ឯកសារភ្ជាប់សាធារណៈ ១២ ទំព័រ ៤។

លោក Hinton មិនមានជំហរក្នុងការជួយដល់តុលាការក្នុងលក្ខណៈអព្យាក្រិត និងប្រកបដោយវត្ថុវិស័យនោះទេ ហើយអាស្រ័យហេតុនេះហើយ ភស្តុតាងរបស់គាត់ (រួមទាំងសៀវភៅរបស់គាត់) គឺនឹងមិនមានទម្ងន់ឡើយ។

*(iii)* ***ឯកសារទាក់ទងនឹងការប្រព្រឹត្តលើជនជាតិវៀតណាម និង ពុទ្ធសាសនិក***

19. មេធាវីការពារក្តីបានអះអាងជាញឹកញាប់ថា មិនមានគោលនយោបាយណាមួយក្នុងការបំផ្លាញជនជាតិវៀតណាម ឬចាម ឬក៏ពុទ្ធសាសនិកឡើយ នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ (ឬក៏គោលនយោបាយក្នុងការប្រព្រឹត្តបទល្មើសនេះទេ)។ ខ្លួនបានពន្យល់អំពីផែនការដែលមានបំណងវាយរំលំមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជា ដែលមាននៅក្នុងគ្រប់ថ្នាក់នៅក្នុងបក្សកុម្មុយនិស្តកម្ពុជា រួមទាំងបុគ្គលថ្នាក់ខ្ពស់ដូចជា សោ ភឹម រស់ ញឹម វ៉ន វ៉េត និង កុយ ធួន ដែលមានការគាំទ្រពីប្រទេសវៀតណាម។ បុគ្គលមួយចំនួនត្រូវបានចាប់ខ្លួនដោយមានមូលហេតុគួរឱ្យជឿជាក់បានថា បុគ្គលទាំងនេះបានចូលរួមក្នុងផែនការក្បត់ គឺមិនទាក់ទងនឹងជាតិសាសន៍ ឬក៏សាសនារបស់គេឡើយ[28]។ ដោយសារតែសៀវភៅរបស់លោក Hinton ពិភាក្សាអំពីទំនាក់ទំនងរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម និងផលប៉ះពាល់នៃទំនាក់ទំនងរវាងប្រទេសទាំងពីរទៅលើការប្រព្រឹត្តលើជនជាតិវៀតណាមនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ[29] ដូចនេះមេធាវីការពារក្តីនឹងសួរគាត់អំពីទំនាក់ទំនងនេះ និងអំពីសារសំខាន់ និងផលប៉ះពាល់នៃទំនាក់ទំនងជាប្រវត្តិសាស្ត្ររវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម។

20. ឯកសារ ១៣ គឺជាការបោះពុម្ពផ្សាយដោយលោក Hinton ដែលមានចំណងជើង "យុត្តិធម៌អន្តរកាល (Transitional Justice Time): Uncle Sam, Aunty Yan, and the Khmer Rouge Tribunal") ដែលត្រូវបានបោះពុម្ពផ្សាយក្នុងសៀវភៅមួយដែលមានចំណងជើង *"នៅក្នុងប្រល័យពូជសាសន៍ និង អំពើសាហាវយង់ឃ្នងនៅអាស៊ី (In Genocide and Mass Atrocities in Asia): កេរ្តិ៍ដំណែល និងការទប់ស្កាត់* ដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់ដោយ Deborah Mayerson និង Annie Pohlman, Routledge, 2013 ។ ឯកសារនេះមាននៅក្នុង**ឯកសារភ្ជាប់ធារណៈ១៣** ។

---

[28] សូមមើល **F2/8** "សំណើលើកទី ៦ របស់ នួន ជា ស្នើសុំឱ្យមានការពិចារណា និងទទួលយកភស្តុតាងបន្ថែម ទាក់ទិននឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០១៥ កថាខណ្ឌ ២៣ ដល់ ៦៩។

[29] **E3/3346**, Hinton, *Why Did They Kill?* pp. 213-220 (ERN EN: 00431655-00431662).

នៅក្នុងអត្ថបទនេះលោក Hinton ពិភាក្សាយុត្តិធម៌អន្តរកាល និងផលប៉ះពាល់មកលើជនរងគ្រោះតាមរយៈឧបទាហរណ៍ អរតក និង កម្ពុជា ។ លោក Hinton កត់សម្គាល់ថាយុត្តិធម៌អន្តរកាលមាននិន្នាការ "លុបចោលភាពស្មុគ្រស្មាញប្រវត្តិសាស្ត្រ និងវប្បធម៌សង្គម"[30]។

គាត់សរសេរថា នៅ អ.វ.ត.ក:

> អ្វីដែលបានកើតឡើងនៅមុនឆ្នាំ១៩៧៥ និងនៅចន្លោះឆ្នាំ១៩៧៩ និង ឆ្នាំ២០០៣ គឺធ្វើឲ្យរាបស្មើ និងលុបចោលនូវស្នាមលុបពេលវេលា ដែលជាសញ្ញាសំគាល់នៃយុត្តិធម៌អន្តរកាលដែលបែកចេញជាពីរ។ និយាយម្យ៉ាងទៀតយុត្តិធម៌អន្តរកាល យកចេញពីបរិបទប្រវត្តិសាស្ត្រ (de-historicize) ដែលផ្ទុយពីការពិតដែលតែងតែពាក់ព័ន្ធជាមួយគ្នា ។ យើងមិនបានរៀនអ្វីទាំងអស់ពីប្រភពដើម ឬ លទ្ធផលភ្លាមៗនៃជម្លោះ ដូចជាសង្គ្រាមវៀតណាម ឬ ភូមិសាស្ត្រនយោបាយដែលបានជួយសង្គ្រាមរហូតដល់ចុងទស្សវត្សរ៍ឆ្នាំ១៩៩០[31]។

គាត់កត់សម្គាល់បន្ថែមទៀតថា:

> ថ្វីបើការអះអាងដែលឮជាញឹកញាប់ថា តុលាការខ្មែរក្រហមនឹងបង្ហាញ "ការពិត" ក៏យុត្តិធម៌អន្តរ កាលពាក់ព័ន្ធស្នាមលុប ដែលជាការយល់ធំទូលាយនៃសង្គម ប្រវត្តិសាស្ត្រ និងភូមិសាស្ត្រនយោបាយកម្ពុជា-ដែលបាត់ពីចក្ខុ ធ្វើឲ្យចុះថយនៃការយល់ដឹង និងបង្កើតការពិតដែលបាត់ពន្លឺ [32]។

21. លោក Hinton បានសន្និដ្ឋានថា:

> ដើម្បីស្វែងរកការយកចេញការសន្មតជាមុននៃយុត្តិធម៌អន្តរកាល គឺមិនមែនជាការបដិសេធដោយសាមញ្ញនោះទេ ។ យើងត្រូវចាប់ផ្តើមសិក្សាយុត្តិធម៌អន្តរកាល ដែលអនុញ្ញាតឲ្យយើងទទួលស្គាល់ចំណុចចន្លោះប្រហោងនៅក្នុង និង ស្រមោលនៅខាងក្រោយដែលត្រូវបានសន្មតជាមុន និង ធ្វើឲ្យទៅធម្មតា ។ ជាពិសេសមនោគតិនេះមាននិន្នាការលុបចោលប្រវត្តិសាស្ត្រ និងភាពស្មុគ្រស្មាញវប្បធម៌សង្គម ដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងទ្រព្យនៃការពិតដែលអាចទាញធម្មនិយាមបានតាមការសន្មតជាមុន "ការទប់ស្កាត់" និង "ការយល់ពីអតីតកាល" ដែលជាញឹកញាប់ត្រូវបានគេអះអាងនៅក្នុងវោហារសាស្ត្រយុត្តិធម៌អន្តរកាល ។ សូម្បីសម្រាប់អ្នកគាំទ្រខ្លាំងម្នាក់នៃគំនិតផ្តួចផ្តើមយុត្តិធម៌អន្តរកាល ដូចជាការយល់គឺសំខាន់ខ្លាំងណាស់

[30] ឯកសារភ្ជាប់សាធារណៈ:១៣ នៅទំព័រ ៩៦ កថាខណ្ឌទី២ ។

[31] ឯកសារភ្ជាប់សាធារណៈ:១៣ នៅទំព័រ ៩១-៩២ ។

[32] ឯកសារភ្ជាប់សាធារណៈ:១៣ នៅទំព័រ ៩២ កថាខណ្ឌទី២ ។

សម្រាប់ជម្រើសមធ្យោបាយនានា ដែលយន្តការសម្រាប់ដោះស្រាយកេរ្តិ៍ដំណែលពីអតីតកាល អាចលាតត្រដាង។ ដើម្បីមិនអើពើដឹង ការគិតដ៏សំខាន់នេះ គឺជាហានិភ័យដែលបន្សល់នៅ ដូចជាការបង្កើត Uncle San ដែលមិនស្គាល់នៅក្នុងគេហទំព័រយុត្តិធម៌អន្តរកាល[33] ។

22. ឯកសារ ១៤ គឺជាអត្ថបទមួយដែលនិពន្ធដោយលោក Hinton នៅឆ្នាំ២០១៤ មានចំណងជើង "យុត្តិធម៌ និង ពេលវេលានៅតុលាការខ្មែរក្រហម (Justice and Time at Khmer Rouge Tribunal): ដើម្បីរំឭកដល់ វ៉ាន់ ណាត ជាងគំនូរ និង អ្នកនៅរស់ពីមន្ទីរស២១"។ អត្ថបទនេះត្រូវបានបោះពុម្ពផ្សាយនៅក្នុង *Genocide studies and Prevention* ទស្សនាវដ្តីអន្តរជាតិ និងមាននៅក្នុង**ឯកសារសាធារណៈ ១៤** ។ លោក Hinton ពិនិត្យពីការចូលរួមរបស់ វ៉ាន់ ណាត-អតីតអ្នកទោសស២១-នៅក្នុងការជំនុំជម្រះ ឌុច នៅ អវតក និងទស្សនរបស់លោក វ៉ាន់ ណាត នៃ អវតក។ ក្នុងអំឡុងពេលវិភាគលោក Hinton ប្រកាន់ភ្ជាប់នូវជំហរថាយុត្តាធិការពេលវេលារបស់ អវតក គឺកម្រិត ដើម្បីកុំឱ្យសហរដ្ឋអាមេរិកជំទាស់ ហើយថាយុត្តាធិការពេលវេលារបស់ អវតក ត្រូវកំណត់ផងដែរក្នុងន័យមិនដាក់បញ្ចូលមន្ត្រីកម្ពុជាដែលកំពុងស្ថិតក្នុងអំណាច៖

> កិច្ចព្រមព្រៀងបង្កើត អវតក ដែលអ្នកចរចារប្រើពេលវេលាអស់ជាច្រើនឆ្នាំ រួមបញ្ចូលទាំងយុត្តាធិការពេលវេលាកំណត់ ("ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មកដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩") ដែលនឹងបំពេញចិត្តសហរដ្ឋអាមេរិក និង ចិន មហាអំណាចដែលត្រូវបានដាក់កំហុសនៅក្នុងដើមហេតុ និងលទ្ធផលនៃជម្លោះ និងយុត្តាធិការលើបុគ្គល ("មេដឹកនាំជាន់ខ្ពស់" និង ជនដែលទទួលខុសត្រូវខ្ពស់បំផុត") ដែលទទួលយកដោយមន្ត្រីកម្ពុជាដែលចង់បញ្ចៀសការស៊ើបសួរជាបន្តបន្ទាប់ ដែលអាចធ្វើឱ្យអន្តរាយដល់សន្តិភាព ឬទម្លាក់កំហុសមកលើមេដឹកនាំបច្ចុប្បន្ន ដែលភាគច្រើនគឺជាអតីតខ្មែរក្រហម[34] ។
>
> ក្រៅពីការធ្វើលាបកម្មឌីណាមីតពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រសង្គមទាក់ទងនឹងការងើបឡើងរបស់ខ្មែរក្រហម ដូចជាសង្គ្រាមវៀតណាម និងការទំលាក់គ្រាប់បែកសហរដ្ឋអាមេរិកមកលើជនបទកម្ពុជា យុត្តាធិកាពេលវេលានេះលុបព្រឹត្តិការណ៍សំខាន់ៗដ៏ទៃទៀត ដូចជាការដែលខ្មែរក្រហមបន្ទាប់ពីត្រូវបានផ្ដួលរំលំពីអំណាចត្រូវបានបំពាក់អាវុធដោយសហរដ្ឋអាមេរិក ចិន និង មហាអំណាចផ្សេងទៀត ដោយសារភូមិសាស្ត្រនយោបាយ ។ តាមពិតខ្មែរក្រហមត្រូវបានផ្តល់នូវអសនៈរបស់ កម្ពុជានៅអង្គការសហប្រជាជាតិ។ ទើបតែនៅក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ នៅពេលដែលកម្ពុជារៀបចំដោយអង្គការសហប្រជាជាតិ ដែលមន្ត្រីរដ្ឋាភិបាលបរទេសជាច្រើនចាប់ផ្តើមនិយាយពីការ សម្លាប់រង្គាលដោយខ្មែរក្រហម ដែលផ្ទុយពីការប្រើប្រាស់ពាក្យស្រាល(ឧទាហរណ៍ "ព្រឹត្តិការណ៍ អកុសលនៃអតីតកាល") ដែលត្រូវបានប្រើប្រាស់ជាញឹកញាប់ក្នុង

---

[33] ឯកសារភ្ជាប់សាធារណៈ១៣ នៅទំព័រ ៩៦ កថាខណ្ឌទី២ ។

[34] ឯកសារភ្ជាប់សាធារណៈ១៤ នៅទំព័រ ១១ កថាខណ្ឌទី៥ ។

អំឡុងពេលសង្គ្រាមត្រជាក់។ ព្រឹត្តិការណ៍បែបនេះជាញឹកញាប់ត្រូវបានលុបនៅក្នុងយុត្តាធិការពេលវេលា ដែលសំដៅទៅលើភាពដាច់ៗពីគ្នាពីចន្លោះពេល (ពេល និង ទីកន្លែងនៃបទល្មើស) ការឱ្យផលគាប់ចិត្ត និង ភាពចង្អៀត (ក្នុងន័យដំណើរការតុលាការ) និងវឌ្ឍនភាព (ទៅរកសេចក្តីវិនិច្ឆ័យដោយគុណភាព ការបិទ បញ្ចប់ និងការពិតពីភស្តុតាង)[35]។

23. លោក Hinton មានជំហរថាការកំណត់យុត្តាធិការពេលវេលារបស់ អវតក បង្កឱ្យរូបភាពនៃព្រឹត្តិការមានលក្ខណៈមិនគ្រប់គ្រាន់ ដែលផ្ទុយពីគោលបំណងរបស់ខ្លួនក្នុងស្វែងរកការពិត:

> តែពេលវេលាបង្កើតព្រឹត្តិការណ៍ដ៏ធំនៅ អវតក ហើយវាជាប់ទាក់ទងដោយផ្ទាល់ទៅនឹងវិធីសាស្ត្រ ដែលការពិត និង ចំណេះដឹង ត្រូវបានបង្កើតឡើងនៅតុលាការនេះ ។ ការបង្ហាញជាក់ស្តែងបំផុតនៃចំណុចនេះ គឺយុត្តាធិការពេលវេលា។ អវតក ត្រូវបានអនុញ្ញាតឱ្យពិនិត្យការរំលោភសិទ្ធិមនុស្ស ទ្រង់ទ្រាយធំ ដែលកើតឡើងនៅពេលខ្មែរក្រហមស្ថិតក្នុងអំណាច-មិននៅមុន និងមិននៅក្រោយខ្មែរក្រហមស្ថិតក្នុងអំណាចនោះទេ ។ ដោយសារផ្ទុយទៅនឹងការធ្វើប្រវត្តិភាពនៃការយល់នៃអំពើប្រល័យពូជសាសន៍ តុលាការត្រូវបានផ្តល់យុត្តាធិការកំណត់មួយ[36] ។
>
> ឧទាហរណ៍ការជំនុំជម្រះ ឌុច បានលាតត្រដាងរឿងរ៉ាវថ្មីអំពីដំណើរការនៅ ស២១ តែដោយផ្តោត លើឆ្នាំដែលខ្មែរក្រហមកាន់កាប់កម្ពុជា **ទីបំផុតសំណុំរឿងបង្កើត "ការពិត" ដែលបានធ្វើឱ្យនៅតែមិនច្បាស់លាស់អំពីដំណើរការប្រវត្តិសាស្ត្រ** និងការយល់ឃើញកត្តាទាំងឡាយដែលជួយខ្មែរក្រហមឡើងកាន់អំណាច[37]។
>
> **ប្រសិនបើគោលបំណងសំខាន់មួយរបស់តុលាការនេះ គឺលាតត្រដាងការពិតដែលត្រូវបានលាក់បាំងដោយនយោបាយនៃការធ្វើឱ្យនឹកឃើញឡើងវិញ អញ្ចឹងទេហេតុអ្វីបានជាមិនប្រើប្រាស់វចនាសម្ព័ន្ធ និង ឫសគល់នៃអំពើប្រល័យពូជសាសន៍ និងវិធីសាស្ត្រនានាដែលជាប់ទាក់ទងជាមួយ នយោបាយទៅ?**[38]

24. លោក Hinton សន្និដ្ឋានថា "យុត្តាធិការពេលវេលារបស់តុលាការខ្មែរក្រហមរំលេចចំណុចនេះ ដោយសារអតីតកាលដែលស្មុគស្មាញ ត្រូវបានថ្លែងមិនអស់សេចក្តី បើទោះបីការអះអាងពិតត្រូវបានធ្វើក៏ដោយ។ អនុលោមតាមតក្កវិជ្ជារបស់វាយុត្តាធិការដែលមានថេរៈវេលាខ្លីនេះ គឺប្លែក ដូច្នេះ ការពិត គឺតម្រូវចាំបាច់ដើម្បីបញ្ចប់ តែទម្រង់យុត្តាធិការពេលវេលានៃយុត្តិធម៌អន្តរកាល គឺដំណើរការដែលរួញខ្លី ហើយដូច្នេះវាជាប្រវត្តិសាស្ត្រដែលមិនពេញលេញ។ នៅទីបញ្ចប់ការយល់ច្បាស់

---

[35] ឧបសម្ព័ន្ធសាធារណៈ១៤ នៅទំព័រ ១១ កថាខណ្ឌទី៦ ។

[36] ឧបសម្ព័ន្ធសាធារណៈ១៤ នៅទំព័រ ១០ Judicial Time កថាខណ្ឌទី២ ។ (បញ្ជាក់បន្ថែម)

[37] ឧបសម្ព័ន្ធសាធារណៈ១៤ នៅទំព័រ ១១ កថាខណ្ឌទី៣ ។ (បញ្ជាក់បន្ថែម)

[38] ឧបសម្ព័ន្ធសាធារណៈ១៤ នៅទំព័រ ១១ កថាខណ្ឌទី៤ ។ (បញ្ជាក់បន្ថែម)

លាស់ ស្នើយើងឲ្យធ្វើការផ្ទុះបញ្ចាំងសន្ទតជាមុននៃយុត្តិធម៌អន្តរកាល និងសួរថាអ្វីទៅជាការពិតដែលត្រូវបង្កើត និងសម្រាប់មូលហេតុអ្វី”[39]។

25. ឯកសារ ១៣ និងឯកសារ ១៤ ពាក់ព័ន្ធនឹងជំហររបស់មេធាវីការពារក្តីថា ការពិតមិនអាចសម្រេចបានទេ បើគ្មានការវិភាគស៊ីជម្រៅនៃប្រវត្តិសាស្ត្ររបស់កម្ពុជានោះ។ ជាពិសេសការពិតទាក់ទងនឹងការចោទប្រកាន់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តមកលើជនជាតិវៀតណាម ដោយសារជំហររបស់មេធាវីការពារក្តី គឺវៀតណាមគាំទ្រការបះបោរផ្ទៃក្នុងនៅកម្ពុជា ដើម្បីសម្រេចឲ្យបានគោលបំណងប្រវត្តិសាស្ត្ររយៈពេលយូររបស់ខ្លួនក្នុងការបញ្ចូលកម្ពុជាក្នុងសហព័ន្ធឧណ្ឌូចិន ហើយការជាប់ពាក់ព័ន្ធនៅក្នុងការបះបោរនេះ ជំរុញឲ្យចាប់ខ្លួនបុគ្គលជាច្រើនក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ ។ អនុលោមតាមអង្គជំនុំជម្រះសាលាដំបូងលោក Hinton ជាអ្នកជំនាញម្នាក់លើការប្រព្រឹត្តមកលើជនជាតិវៀតណាម ដូច្នេះមេធាវីការពារក្តីមានបំណងសួរដេញដោលគាត់លើប្រធានបទនេះ។ ម្យ៉ាងទៀតឯកសារនេះ ក៏ពាក់ព័ន្ធទៅនឹងបរិបទនៃការស្រាវជ្រាវរបស់លោក Hinton នៅកម្ពុជា និងការរៀបចំសៀវភៅរបស់គាត់ *Why Did They Kill?*

26. ឯកសារ ១៥ គឺជាអត្ថបទមួយដែលសរសេរដោយ William A. Schabas នៅឆ្នាំ២០០១ ដែលមានចំណងជើង “បញ្ហានៃការដាក់ឲ្យទៅជាច្បាប់ (Problem of International Codification) - ថាតើអំពើសាហាវយង់ឃ្នងនៅកម្ពុជា និង កូសូវ៉ូ គឺជាប្រល័យពូជសាសន៍?” អត្ថបទនេះអាចរកឃើញនៅក្នុង**ឯកសារសាធារណៈ១៥**។ លោក Schabas ជាសាស្ត្រាចារ្យច្បាប់សិទ្ធិមនុស្ស និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិដ៏ល្បីឈ្មោះ ពិភាក្សាអត្ថិភាពនៃអំពើប្រល័យពូជសាសន៍នៅក្នុងទិដ្ឋភាពច្បាប់នៅកម្ពុជាក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។ គាត់មានជំហរថា បទល្មើសដែលត្រូវបានប្រព្រឹត្ត ជាផ្នែកនៃគោលនយោបាយ ដែលជាទូទៅមិនបំពេញលក្ខខណ្ឌជាអំពើប្រល័យពូជសាសន៍:

> ការបំផ្លិចបំផ្លាញស្ថាប័នវប្បធម៌ និងសមានកម្មដោយបង្ខំ គឺជាបច្ចេកទេសដ៏មានប្រសិទ្ធិភាពបំផុត សម្រាប់ការបំផ្លាញក្រុមសាសនា ឬ ក្រុមជាតិពន្ធុ ។ វាត្រូវបានហាមដោយច្បាប់អន្តរជាតិ ។ បញ្ហានៅទីនេះ គឺថាអំពើទាំងនេះ គឺមិនមែនជាអំពើប្រល័យពូជសាសន៍នៅក្នុងវិសាលភាពនៃ មាត្រា II នៃអនុសញ្ញា[40] ។

[39] ឧបសម្ព័ន្ធសាធារណៈ១៤ នៅទំព័រ ១៣ កថាខណ្ឌទី៤ ។ (បញ្ជាក់បន្ថែម)

[40] ឧបសម្ព័ន្ធសាធារណៈ១៥ នៅទំព័រ ២៤១ ។

27. ដូច្នេះឯកសារ១៥ ផ្ទុយពីជំហររបស់លោក Hinton ដែលថាអំពើប្រល័យពូជសាសន៍បានកើតឡើងនៅកម្ពុជា និងគាំទ្រជំហររបស់មេធាវីការពារក្តីដែលថា ការចោទប្រកាន់ទាក់ទងនឹងការប្រព្រឹត្តមកលើជនជាតិចាម ឬ វៀតណាម មិនធ្លាក់ក្នុងវិសាលភាពនៃអនុសញ្ញាប្រល័យពូជសាសន៍ទេ។

28. ឯកសារ១៦ គឺជាអត្ថបទមួយដែលចំណងជើង "ការស្វែងរកយុត្តិធម៌នៅវាលពិឃាត (Seeking justice in the killing fields" ដែលនិពន្ធឡើងដោយលោក Hinton និងបានបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដី *The New York Times* កាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២00៦។ វាមាននៅក្នុង **ឯកសារសាធារណៈ១៦** ។ លោក Hinton ពិភាក្សាការបង្កើត អវតក ដោយលើកពីការបារម្ភមួយចំនួន រួមទាំងថវិការ អាយុរបស់ជនជាប់ចោទ និង ឯករាជ្យរបស់ អវតក ។ លោក Hinton កត់សម្គាល់ថា៖

> មានក្តីបារម្ភណ៍ធ្ងន់ធ្ងរដែលបុគ្គលិកផ្នែកច្បាប់មិនមានការបណ្តុះបណ្តាលគ្រប់គ្រាន់ ឬ ឯករាជ្យ ដែលនាំឲ្យកើតមាននូវលទ្ធភាពដែលថា តុលាការនេះនឹងត្រូវទទួលរងឥទ្ធិពលពីមេដឹកនាំកម្ពុជា ហើយនឹងមិនបំពេញបទដ្ឋានច្បាប់អន្តរជាតិផងដែរ។ ការបារម្ភណ៍នេះត្រូវបានរំលេចឡើងនៅ ពេលបញ្ជីឈ្មោះមន្ត្រីតុលាការកម្ពុជា ត្រូវបានរកឃើញថាមានបញ្ចូលចៅក្រម ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៃគណបក្សប្រជាជនកម្ពុជា (CPP) រួមទាំងឧត្តមសេនីយយោធាផងដែរ ដែលត្រូវបានគេរាយការណ៍ថា ជាសមាជិកគណៈកម្មាធិការមជ្ឈឹមរបស់ CPP ហើយធ្លាប់បានធ្វើប្រធានចៅក្រមជំនុំជម្រះលើករណីពីររឿង ដែលកាលៈទេសៈជុំវិញការកាត់សេចក្តីនេះហ៊ុំព័ទ្ធដោយមន្ទិលសង្ស័យ ដែលនាំការវិនិច្ឆ័យទោសលាយឡំរឿងនយោបាយ ។

29. ឯកសារ ១៦ គឺពាក់ព័ន្ធទៅនឹងសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ មេធាវីការពារក្តីតែងតែជំទាស់និត្យានុកូលភាព និងអនាគតរបស់ អវតក ដែលប៉ះពាល់សឹងតែគ្រប់ទិដ្ឋភាពនៃសំណុំរឿង ។ លោក Hinton ដែលអង្គជំនុំជម្រះសាលាដំបូងចាត់ទុកថា ជាអ្នកជំនាញ និងបានចំណាយពេលច្រើនឆ្នាំធ្វើកិច្ចការលើបុព្វហេតុ និងផលវិបាកនៃរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងលើបញ្ហាជាច្រើនទៀតដែលទាក់ទងនឹងយុត្តិធម៌សម្រាប់ជនរងគ្រោះ អាចផ្តល់ព័ត៌មានមានតំលៃដែលនិយាយលំអិតថាតើផលប៉ះពាល់ទាំងនោះជាអ្វី និងរៀបរាប់ពីចំណុចខ្វះខាតនៃការស្រាវជ្រាវយុត្តិធម៌អន្តរកាលសម្រាប់ការពិត ។

30. ឯកសារ ១៧ គឺជាការពិពណ៌នាពីសន្និសិទមួយស្តីពីដែនកំណត់នៃការនឹកឃើញ *(The Limit of Memory)* ដែលប្រព្រឹត្តទៅនៅថ្ងៃទី៦ ខែ មីនា ឆ្នាំ ២0១0 ហើយជាកន្លែងដែលលោក Hinton ធ្វើបទបង្ហាញស្តីពី "juridical memory នៅ អវតក"។ អត្ថបទនេះមាននៅក្នុង**ឯកសារភ្ជាប់**

**សារធារណៈ ១៧**។ ខណៈដែលខ្លឹមសារនៃបទបង្ហាញរបស់លោក Hinton មិនអាចរកបាន តែកម្មវត្ថុនៃសន្និសិទនេះត្រូវបានពិពណ៌នាថា "គ្រប់សកម្មភាពនៃការនឹកឃើញ ក៏ថ្លែងបញ្ចិតពីការបំភ្លេច និងការកសាងឡើងវិញនូវអតីតកាល ដែលជាញឹកញាប់ស្របតាមតម្រូវការនយោបាយបច្ចុប្បន្ន ឬតម្រូវការផ្នែកវប្បធម៌ ។ សន្និសិទនេះដោះស្រាយភាពដាក់កម្រិតមួយចំនួនចំពោះទ្រឹស្តី និង ការអនុវត្ត នៃការនឹកឃើញ ដោយផ្តោតលើរបៀបប្រើប្រាស់ និងការរំលោភការនឹកឃើញ ដែលជាញឹកញាប់ចងភ្ជាប់ជាមួយគ្នា"។ វាគឺជាជំហររបស់មេធាវីការពារក្តីថា ក្នុងពេលសង្គ្រាម បុគ្គលដែលរស់នៅក្រោមស្ថានភាពតានតឹងក្នុងចិត្ត មិនអាចនឹកឃើញនូវព្រឹត្តិការណ៍ទាំងនោះ និង មិនអាចពិពណ៌នាឲ្យបានគ្រប់គ្រាន់ដើម្បីផ្តល់ជាមូលដ្ឋានមួយ ដើម្បីបង្កើតកំហុសឲ្យហួសពីវិមតិសង្ស័យបានទេ។ ម្យ៉ាងទៀតមេធាវីការពារក្តីក៏យល់ឃើញដែរថា នៅក្នុងករណីមួយចំនួនការនឹកឃើញរបស់បុគ្គលម្នាក់អាចជំនួសដោយ "ការនឹកឃើញជាសមូហភាព" តាមរយៈសកម្មភាពផ្សព្វផ្សាយទូលំទូលាយដល់សាធារណជនបីរឿងរ៉ាវនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលមិនអើពើប្រវត្តិសាស្ត្រ តួនាទីរបស់វៀតណាម និង សហរដ្ឋអាមេរិក និង អំពើកាចសាហាវរបស់ ប.ក.ក ។

31. មេធាវីការពារក្តីយល់ឃើញថា ឯកសារនេះគឺពាក់ព័ន្ធដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការសួរដេញដោលលោក Hinton ទាក់ទងនឹងខ្លឹមសារនៃបទបង្ហាញរបស់គាត់ និងជាពិសេសលើបញ្ហានៃការប៉ះទង្គិចយ៉ាងខ្លាំង និងភាពត្រឹមត្រូវនៃការនឹកឃើញរបស់បុគ្គលដែលបានរស់នៅឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ។ ដោយពិចារណាថាស្នាដៃរបស់លោក Hinton ផ្តោតលើទិដ្ឋភាពសង្គម និង នរវិទ្យារបស់ "ជនរងគ្រោះ" ដូចដែលបានបង្ហាញដោយការបោះពុម្ពផ្សាយជាច្រើនរបស់គាត់លើបញ្ហានេះ និងជាពិសេសការប៉ះទង្គិចដែលកើតឡើងចំពោះពួកគេ និងការចូលរួមរបស់ពួកគេនៅក្នុងយុត្តិធម៌អន្តរកាល[41] គាត់អាចផ្តល់ការយល់ដឹងជ្រៅជ្រះទៅលើបញ្ហានៃការនឹកឃើញជាសមូហភាព និងផលប៉ះពាល់នៃការប៉ះទង្គិចលើការនឹកឃើញ បញ្ហាដែលទាក់ទងជិតស្និទជាមួយភាពអាចជឿជាក់បានរបស់សាក្សី និងភាពត្រឹមត្រូវនៃភស្តុតាង ។ ម្យ៉ាងទៀតដូចដែលបានបង្ហាញដោយឯកសារ១៣ និងឯកសារ១៤ ខាងលើលោក Hinton យល់ឃើញថាការវិភាគប្រវត្តិសាស្ត្រ និងវប្បធម៌នៅកម្ពុជា គឺសំខាន់ជាទីបំផុតដើម្បីយល់ពីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ រួមទាំងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ថាប្រឆាំងនឹងវៀតណាម និងអ្នកកាន់ពុទ្ធសាសនា។ ជាចុងក្រោយឯកសារ ១៦, ១៧ និង ឯកសារ១៨ ក៏អាចផ្តល់បរិបទដែលពាក់

[41] សូមមើលឧបសម្ព័ន្ធសាធារណៈ១ ការបោះពុម្ពផ្សាយ ។

ព័ន្ធទៅនឹងការវាយតំលៃសៀវភៅរបស់លោក Hinton និងសក្ខីកម្មរបស់គាត់នាពេលខាងមុខ ។

## ខ. ឯកសារមិនអាចរកបាននៅមុនការចាប់ផ្តើមការជំនុំជម្រះ ឬត្រូវទទួលយកជាភស្តុតាងដើម្បីផលប្រយោជន៍យុត្តិធម៌

32. អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០២ ចាប់ផ្តើមនៅខែមិថុនា ឆ្នាំ២០១១[42] ។ នៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងភាគីថាលោក Hinton នឹងត្រូវផ្តល់សក្ខីកម្មនៅសប្តាហ៍ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦[43] ។ នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងសម្រេចថាលោក Hinton នឹងត្រូវកោះហៅជាសាក្សីជំនាញដើម្បីផ្តល់សក្ខីកម្មលើ "បញ្ហាទាំងអស់ក្នុងរង្វង់នៃការដឹង ឬ ជំនាញរបស់គាត់ជាពិសេសពាក់ព័ន្ធទៅនឹងការប្រព្រឹត្តមកលើជនជាតិវៀតណាម និងអ្នកកាន់ពុទ្ធសាសនានៅក្នុងសំណុំរឿង ០០២/០២"[44]។ ជាខ្លឹមភាគីមិនបានដឹងថាលោក Hinton នឹងចូលខ្លួនជាសាក្សីនៅក្នុងសំណុំរឿងនេះទេ រហូតដល់បីសប្តាហ៍កន្លងទៅនេះ ហើយមិនបានដឹងវិសាលភាពនៃសក្ខីកម្មរបស់គាត់រហូតដល់សប្តាហ៍កន្លងទៅនេះទេ ។

33. ឯកសារ ១, ៣, ៤, ៥, ៨, ១១, ១២, ១៣ និង ឯកសារ ១៤ ត្រូវបានបង្កើតក្រោយឆ្នាំ២០១១ ហើយដូច្នេះមិនអាចរកបាននៅមុនការចាប់ផ្តើមសវនាការជំនុំជម្រះ ។ ខណៈដែលឯកសារ ២, ៦, ៧, ៩, ១០, ១៥, ១៦ និងឯកសារ១៧ អាចរកបាននៅមុនការចាប់ផ្តើមសវនាការជំនុំជម្រះ មេធាវីការពារក្តីមិនអាចគិតជាមុនថានឹងប្រើប្រាស់ឯកសារទាំងនេះទេ ដោយសារមិនដឹងថាលោក Hinton នឹងត្រូវចូលខ្លួនជាសាក្សី ហើយមិនដឹងវិសាលភាពនៃជំនាញរបស់គាត់ រហូតដល់ពេលថ្មីៗនេះទេ ។

---

[42] E307/1 សេចក្តីសម្រេចលើសំណើរួមរបស់ភាគីសុំការបំភ្លឺអំពីការអនុវត្តវិធាន ៨៧(៤) ឯកសារ (E307) និងសេចក្តីជូនដំណឹងរបស់ក្រុមមេធាវីការពារក្តី នួន ជា ស្តីពីការមិនដាក់បញ្ជីភស្តុតាងដែលបានធ្វើបច្ចុប្បន្នភាព (E305/3) ចុះថ្ងៃទី១១ ខែ មិថុនា ឆ្នាំ ២០១៤ នៅកថាខណ្ឌ២ ។ E307/1/2 សេចក្តីសម្រេចលើសំណើរួមសុំឱ្យសម្រេចសាជាថ្មីឡើងវិញលើការអនុវត្តវិធាន៨៧(៤) ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ ២០១៤ នៅកថាខណ្ឌ៦។

[43] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ជូនភាគី ថ្ងៃទី១២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ។

[44] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់ជូនភាគី ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ ២០១៦ ។

34. ម្យ៉ាងទៀតមានតែឯកសារមួយទេ[45]ក្នុងចំណោមឯកសារទាំងអស់ គឺជាការបោះពុម្ពផ្សាយពីលោក Hinton ឬ ការបោះពុម្ពផ្សាយពីអ្វីដែលលោក Hinton បាននិយាយ ។ ឯកសារទាំងនេះពាក់ព័ន្ធយ៉ាងជិតស្និទទៅនឹងឯកសារដែលដាក់រួចហើយនៅចំពោះមុខអង្គជំនុំជម្រះនេះ រួមទាំងសៀវភៅរបស់លោក Hinton *Why Did They Kill*[46]។ ម្យ៉ាងទៀតឯកសារ១ និង ឯកសារ២ គឺពាក់ព័ន្ធទៅនឹងសាវតារ និង ជំនាញរបស់លោក Hinton ហើយឯកសារ១៣ និង ឯកសារ១៧ គឺពាក់ព័ន្ធទៅនឹងសារធាតុនៃភស្តុតាងរបស់គាត់។ ដូច្នេះឯកសារដែលបានស្នើសុំទាំងអស់មានវត្ថុមានតំលៃភវនីយភាពនៃសៀវភៅរបស់គាត់ ព្រមទាំងភស្តុតាងដែលគាត់នឹងផ្តល់នៅក្នុងតុលាការ ។ ដូច្នេះការទទួលយកឯកសារទាំងនេះជាភស្តុតាង នឹងមានប្រយោជន៍ដល់ការបញ្ជាក់ការពិត ។

## គ. ឯកសារដែលបានស្នើសុំ គឺពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០២

35. ឯកសារដែលបានស្នើសុំទាំងអស់ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ទាក់ទងនឹងការប្រព្រឹត្តមកលើជនជាតិវៀតណាម និងបទចោទប្រកាន់ប្រល័យពូជសាសន៍[47] ។ ម្យ៉ាងទៀតដោយសារលោក Hinton ត្រូវបានចាត់តាំងជាសាក្សីជំនាញដោយអង្គជំនុំជម្រះសាលាដំបូង គាត់ត្រូវតែផ្តល់សក្ខីកម្មលើបញ្ហាទាំងអស់នៅក្នុងវង្វង់នៃចំណេះដឹង និងជំនាញរបស់គាត់ ជាពិសេសពាក់ព័ន្ធទៅនឹងការប្រព្រឹត្តមកលើជនជាតិវៀតណាម និងអ្នកកាន់ពុទ្ធសាសនានៅក្នុងសំណុំរឿង០០២/០២ ដោយភាពអព្យាក្រិត្យ និងភាពត្រឹមត្រូវខ្ពស់បំផុត[48]។ ជាអ្នកជំនាញលោក Hinton មិនអាចផ្តល់មតិយោបល់លើបញ្ហាអង្គហេតុឡើយ[49]។ ឯកសារ១ ដល់ឯកសារ១២ ពាក់ព័ន្ធសាវតារ ជំនាញ និង អនាគតិរបស់គាត់ អាស្រ័យហេតុនេះវាពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការចាត់តាំងជាអ្នកជំនាញ។

36. ឯកសារ ៤ ដល់ឯកសារ១២ បង្ហាញថាលោក Hinton បានធ្វើសេចក្តីសន្និដ្ឋានរួចហើយទាក់ទងនឹងបញ្ហាស្នូលនៃសំណុំរឿងនេះ-ជាពិសេសការសន្និដ្ឋានថាមានប្រល័យពូជសាសន៍នៅកម្ពុជា និងថាជនជាប់ចោទមានតួនាទីជាក់លាក់នៅក្នុងអំពើប្រល័យពូជសាសន៍នេះ ហើយដូច្នេះគាត់បាន

---

[45] ឯកសារ ១៥ ។

[46] E3/3346, Hinton, *Why Did They Kill*?

[47] ឯកសារ D427 "ដីកាដំណោះស្រាយ" ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ នៅកថាខណ្ឌ ៧៤០-៧៤៤ (ការប្រព្រឹត្តមកលើអ្នកពុទ្ធសាសនា) និង កថាខណ្ឌ៧៩១-៨៤១ (ការប្រព្រឹត្តមកលើជនជាតិវៀតណាម) ។

[48] ឯកសារ E215 សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ នៅកថាខណ្ឌ១៥ ។

[49] ឯកសារ E215 សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ នៅកថាខណ្ឌ១៦ ។

ផ្តល់ការសន្និដ្ឋានលើបញ្ហាអង្គហេតុ។ ចំណុចនេះរារាំងគាត់មិនឱ្យផ្តល់សក្ខីកម្មដោយភាពអព្យាក្រិត្យ និងភាពត្រឹមត្រូវឡើយ និងបង្ហាញថាភស្តុតាងជំនាញរបស់លោក Hinton ត្រូវបានធ្វើឱ្យប្រឡាក់ ហើយដូច្នេះមិនមានទម្ងន់ត្រូវពិចារណាឡើយ ។

37. ចុងក្រោយឯកសារ១៣ ដល់ឯកសារ១៧ ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តមកលើជនជាតិវៀតណាម និងជនជាតិភាគតិចដទៃទៀតក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ។ ដូចបញ្ជាក់ខាងលើឯកសារទាំងផ្តល់បរិបទប្រវត្តិសាស្ត្រសម្រាប់ការចោទប្រកាន់ទាក់ទងនឹងការប្រព្រឹត្តមកលើជនជាតិវៀតណាម និងជនជាតិភាគតិចដទៃ ហើយក៏ពាក់ព័ន្ធទៅនឹងបរិបទសម្រាប់ការស្រាវជ្រាវលោក Hinton នៅកម្ពុជា និងការរៀបចំសៀវភៅរបស់គាត់ Why Did They Kill? ដែលពិភាក្សាទំនាក់ទំនងរវាងវៀតណាម និងកម្ពុជា[50] ។ ឯកសារ ១៥ ក៏គាំទ្រជំហររបស់មេធាវីការពារក្តីដែលថា មិនមានគោលនយោបាយដើម្បីបំផ្លិចបំផ្លាញជនជាតិភាគតិច ដូចជាចាម វៀតណាម ឬ អ្នកកាន់ពុទ្ធសាសនា នៅកម្ពុជាក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យនោះទេ។

38. មេធាវីការពារក្តីសូមរំលឹកថា នៅក្នុងសំណើដូចគ្នាទៅនឹងសាក្សីអ្នកជំនាញ អ៊ីសា ឧស្មាន សហព្រះរាជអាជ្ញា មិនបានជំទាស់ទៅនឹងការទទួលយកឯកសារជាភស្តុតាងដែលត្រូវបាននិពន្ធដោយសាក្សី[51]។

## ឃ ឯកសារអាចជឿជាក់បាន និងប្រកបដោយយថាភាព

39. គ្រប់ឯកសារទាំងអស់នេះបំពេញតាម *ការពិនិត្យបឋម (prima facie)* នៃភាពអាចឱ្យជឿជាក់បាន។ ឯកសារ ១, ៥, ៦, ៧ និង ៨ យកពីគេហទំព័ររបស់សកលវិទ្យាល័យ Rutgers-Newark ដែលគាត់ជាសាស្ត្រាចារ្យនៅទីនោះ។ ឯកសារ ២, ៩ ដល់ ១១, ១៣ ដល់ ១៤ និង ១៧

---

[50] E3/3346 Hinton, Why Did They Kill? Pp 215-220 (ERN:0043657-00431662)

[51] ប្រតិចារិកថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១៦ (ការជំទាស់ទៅនឹងសំណើវិធាន ៨៧របស់ នួន ជា **E1/387.1**) ទំព័រ ១០៤ ទៅដល់ ១០៥ ("ឯកសារនេះ និងឯកសារមួយចំនួនទៀតដែលជាសេចក្តីថ្លែងការរបស់សាក្សី ដែលយើងមិនជំទាស់ទេ ហើយយើងអាចដឹងថា ឯកសារទាំងនោះមានភាពពាក់ព័ន្ធ និងជួយដល់អង្គជំនុំជម្រះក្នុងការស្វែងរកការពិត ប្រសិនបើឯកសារទាំងនោះត្រូវបានទទួលយក។ យើងខ្ញុំមិនមានការជំទាស់ទេ") ទំព័រ ១០៦ ដល់ ១០៧។ ("សម្រាប់ឯកសារភ្ជាប់ ៤ វាគឺជាឯកសារដែលនិពន្ធឡើងដោយសាក្សី ហេតុដូចនេះហើយ យើងខ្ញុំគិតថា វាជាការសមស្របក្នុងការទទួលយកជាភស្តុតាងសម្រាប់សក្ខីកម្មរបស់2-TCE-95"។

សរសេរដោយលោក Hinton និង/ឬ មាននៅក្នុងប្រវត្តិរូបសង្ខេបរបស់គាត់។ ឯកសារ ៤ យកចេញពីគេហទំព័ររបស់ DC-Cam។ ឯកសារ ១៥ សរសេរដោយ William Schabas ដែលជាអ្នកច្បាប់ដ៏ល្បីម្នាក់ស្មើយរូប។ ជាចុងក្រោយគឺឯកសារ ៣, ១២ និង ១៥ ត្រូវបានបោះពុម្ពផ្សាយដោយសារព័ត៌មានល្បីៗ ដូចជា *Ukrainian Weekly*[52] និង *Al-Jazeera*[53]។

IV. **សំណើសុំ**

40. ដោយសារហេតុផលទាំងអស់ដែលបានលើកឡើងនេះ មេធាវីការពារក្តីស្នើសុំដោយគោរពដល់អង្គជំនុំជម្រះឲ្យទទួលយកឯកសារទាំង១៧នេះ ដាក់ចូលក្នុងសំណុំរឿង ០០២/០២។

**សហមេធាវីការពារក្តីរបស់ នួន ជា**

**សុន អរុណ** **Victor KOPPE**

[52] ប្រភព http://www.ukrweekly.com/uwwp/archive/. ។

[53] ប្រភព : http://www.aljazeera.com/indepth/features/2013/04/201341891039959566.html។